# ប្រយ័ត្នចំពោះការលក់ទូរសព្ទ័ក្នុងបំណងអាក្រក់ទៅដល់សិក្ខាកាម!!

ថ្មីៗនេះ មានករណីពាក់ព័ន្ធកុងត្រានៃការជួលប្រព័ន្ធអ៊ីនធឺណេតចល័ត និងទូរសព្ទ័មានការកើនឡើងច្រើន។ក្នុងនោះមានករណីទាមទារជាទឹកប្រាក់ដ៏ច្រើនម៉ឺនយ៉េនផងដែរ។ សូមប្រុងប្រយ័ត្នចំពោះការឆបោកតាមវិធីផ្សេងៗដូចខាងក្រោម

**ដំបូងការផ្សព្វផ្សាយពីបណ្តាញសង្គម Facebook**

នៅលើបណ្តាញសង្គម Facebook មាន「ការចុះកិច្ចសន្យាងាយៗជាមួយទូរសព្ទ័ស្មាតហ្វូន」និង「អាចទិញទូរសព្ទ័បានក្នុងតំលៃថោក」ផ្សេងៗ ដែលមានជាការផ្សាយពាណិជ្ជកម្មមកដល់សិក្ខាកាម។ នៅពេលដែល បំពេញកិច្ចកុងត្រា នឹងមានការសួរព័ត៌មានបន្ថែមអំពី កាតស្នាក់នៅប្រទេសជប៉ុន លិខិតឆ្លងដែន លេខសំគាល់ខ្លួន(My Number) លេខគណនេយ្យធនាគារ អាស័យដ្ឋានស្នាក់នៅ និងបន្តដល់កន្លែងធ្វើការផងដែរ។ នៅពេលបំពេញរួចរាល់ គេនឹងផ្ញើទូរសព្ទ័មកឲ្យ ហើយក្នុងរយ: ៦ខែដំបូង ការបង់ប្រាក់នឹងតាមតំលៃកំណត់ ប៉ុន្តែលើសពី៦ខែឡើងទៅ វានឹងតំឡើងថ្លៃនៃការបង់ប្រាក់ ទ្វេ១ជា២ឬជា៣ដងមិនខាន។

**ពត៍មានផ្ទាល់ខ្លួនត្រូវបានលួចយកទៅប្រើប្រាស់**

ជនឆបោកលក់ទូរសព្ទ័ អាចយកពត៌មាន ឬឈ្មោះរបស់យើងទៅបន្តកុងត្រាទិញទូរសព្ទ័បាន២ទៅ៣គ្រឿងបន្ថែមបាន។ ម៉្យាងទៀត ក៏អាចយកទូរសព្ទ័ទាំងនោះ ទៅបន្តជួលឲ្យជនទី៣ផ្សេងទៀតដែលមិនស្គាល់ ឬលក់ ទទួលបានប្រាក់ជាច្រើនផងដែរ។ ដោយសារតែ ជនឆបោក បានផ្ញើវិក័យប័ត្រ៦ខែដំបូង ទៅកាន់ជនទី៣ដូចនេះ សិក្ខាកាមក៏មិនបានដឹងខ្លួនថា ត្រូវបានគេបោកនោះដែរ។ ក្រុមហ៊ុនទូរសព្ទ័ជាទូទៅ ប្រសិនបើអ្នកមិនបានបង់ប្រាក់ពីខែដំបូង ក្រុមហ៊ុននឹងមានការសង្ស័យ ហើយនឹងលុបចោលនៅកិច្ចកុងត្រាទាំងអស់នោះចោល។ ប៉ុន្តែបើមានការបង់ប្រាក់ត្រឹមត្រូវក្នុងរយ:៦ខែដំបូង ក្រុមហ៊ុនទូរសព្ទ័ផ្ទាល់ក៏មិនមានការចាប់អារម្មណ៍នោះដែរ។ ហើយនៅលើសពីខែទី៦ ជនឆបោកនឹងប្តូរអាសយដ្ឋានបង់ប្រាក់របស់សិក្ខាកាមហើយរត់គេចខ្លួនបាត់។ តំណាក់កាលនោះក្រុមហ៊ុនក៏មិនអាចទំនាក់ទំនងទៅកាន់ជនឆបោកនោះបានដែរ។

**វិធីការពារដើម្បីបញ្ចៀសនៃការរងគ្រោះ**

1. មិនត្រូវទុកចិត្តលើពត៌មានពីបណ្តាញសង្គម Facebook ដែលផ្ញើរមកថា「ទទួលបានផលចំនេញ」។
2. មិនត្រូវបង្ហាញពត៌មានផ្ទាល់ខ្លួនទៅកាន់អ្នកដទៃ។
3. ចំពោះពត៌មានដែលមានពាក់ព័ន្ធនឹងលុយកាក់មិនត្រូវសំរេចចិត្តខ្លួនឯងត្រូវពិភាក្សា ជាមួយជនជាតិជប៉ុននៅក្បែរខ្លួន ឬជាមួយអ្នកបកប្រែ។
4. ទិញទំនិញនៅក្នុងហាងណាដែលអាចទុកចិត្តបាន(អ្នកលក់អ្នកទិញទល់មុខគ្នា) ករណីមានការសង្ស័យលើកាកុងត្រាទិញ ឬចំណាយលើសវ៉ាន់ ត្រូវពិភាក្សាជាមួយអ្នកគ្រប់គ្រងសិក្ខាកាម គ្រូៗដែលទៅសួរសុខទុក្ខ ឬអាចទៅសួរនៅប៉ុស្តិ៍ដែលនៅជិតកន្លែងអ្នក។

## INFORMATION

**ឆ្នាំ២០២០ ការប្រឡងសម្ថភាពភាសាជប៉ុនលើកទី១**
**ថ្ងៃប្រឡង** ខែ៧ ថ្ងៃទី៥
**ថ្ងៃចាប់ផ្តើមទទួលពាក្យ** ខែ៣ ថ្ងៃទី២៧～ខែ៤ ថ្ងៃទី២០
http://info.jees-jlpt.jp/

**សមាជិក ASIA CREATION**

**ខែ៣ ថ្ងៃទី១៥ (អាទិត្យ)** សាខានៅ យ៉ូស្ស៊ូ
**ខែ៤ ថ្ងៃទី១៩ (អាទិត្យ)** សាខាធំនៅ តូក្យូ
※ ពត៌មានលម្អិតផ្តល់ជូនតាមក្រោយ

# ការកាត់ប្រាក់ពីប្រាក់ខែ

TAX

នៅតាមប្រទេសនានា មិនមានប្រទេសណាមួយដែលកាត់ថ្លៃពន្ធ និងថ្លៃធានារ៉ាប់រងពីប្រាក់ខែផ្ទាល់នោះទេ។ អញ្ចឹងហើយទើបចំនួនប្រាក់ដែលទទួលបានហាក់បីដូចជាមានចំនួនខុសគ្នា។ នៅប្រទេសកម្ពុជា និងប្រទេសវៀតណាម ច្បាប់សម្រាប់ការកាត់ប្រាក់គឺដូចគ្នានឹងអ្នកធ្វើការនៅជប៉ុនដែរ។

ខាងក្រោមនេះគឺជាការពិពណ៌នាសង្ខេបនៃការកាត់ប្រាក់ខែ។ អ្វីដែលត្រូវបានដកចេញពីប្រាក់ឈ្នួលត្រូវបានបែងចែកជាពីរប្រភេទ។ ការកាត់ប្រាក់ផ្នែកច្បាប់ និងការកាត់ប្រាក់ផ្សេងទៀត។ ការកាត់ប្រាក់តាមលក្ខន្តិក: ត្រូវបានទទួលស្គាល់និងទាមទារឱ្យដកចេញ ដោយច្បាប់រួមមានពន្ធ(ពន្ធលើប្រាក់ចំណូល និងពន្ធលើពលរដ្ឋ)និងប្រាក់ធានារ៉ាប់រង។ ជនបរទេសដែលកំពុងធ្វើការ នៅប្រទេសជប៉ុន ត្រូវបានកាត់ពន្ធលើប្រាក់ចំណូលប្រចាំខែដែលរដ្ឋាភិបាលជប៉ុន បានចុះសន្ធិសញ្ញាដាច់ដោយឡែកជាមួយរដ្ឋាភិបាល បរទេស។ ដើម្បីការពារការយកពន្ធទ្វេដង។ ជនជាតិខ្មែរនិង ជនជាតិវៀតណាម ដែលបានប្រាក់ឈ្នួលដោយធ្វើការនៅប្រទេសជប៉ុនត្រូវបង់ពន្ធទៅដល់ប្រទេសជប៉ុន។ ពន្ធប្រជាជនគឺជាពន្ធដែលអ្នករស់នៅតាមទីប្រជុំជន និងទីប្រជុំជនដែលទទួលសេវាកម្មសាធារណ:។

ក្រៅពីនេះមានដូចជា ពន្ធធានារ៉ាប់រងសង្គម (ធានារ៉ាប់រងសុខភាព និងធានារ៉ាប់រងប្រាក់សោធននិវត្តន៍របស់និយោជិក) និងធានារ៉ាប់រងកម្លាំងពលកម្ម (ធានារ៉ាប់រងការងារ) ត្រូវបានកាត់ប្រសិនបើក្រុមហ៊ុនអាជីវកម្មបាន បង់ធានារ៉ាប់រងសង្គមនិងធានារ៉ាប់រងកម្លាំងពលកម្ម។ ធានារ៉ាប់រងសង្គមនិងធានារ៉ាប់រងកម្លាំងពលកម្ម(ធានារ៉ាប់រងសុខភាព និងធានារ៉ាប់រងប្រាក់សោធននិវត្តន៍របស់និយោជិក) ត្រូវចំនាយពាក់កណ្តាលដោយ និយោជិកពាក់កណ្តាលទៀត ត្រូវទទួលបានរួមចំណែកពីក្រុមហ៊ុន។

ការកាត់បន្ថយផ្សេងទៀតត្រូវបានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងការងាររវាងក្រុមហ៊ុន និងនិយោជិក។ ប្រសិនបើសិក្ខាកាមយល់ពី ចំនួនទឹកប្រាក់ដែលត្រូវកាត់ច្បាស់ ហើយក្រុមហ៊ុនអាចដកពីប្រាក់ថ្លៃជួលកន្លែងស្នាក់នៅ និង ឧបករណ៍ប្រើប្រាស់ផ្សេងៗ។ ខ្លឹមសារនៃការកាត់ប្រាក់ដែលបានពិពណ៌នាខាងលើមានក្នុង "កិច្ចព្រមព្រៀង កាត់ពីប្រាក់ឈ្នួល" ។

លើសពីនេះ មានការកាត់កងលើបន្ទុកប្តីប្រពន្ធ នៅចុងឆ្នាំដូចគ្នានឹង ជនជាតិ ជប៉ុនដែរ។ អ្នកអាចស្នើប្រាក់កាត់មកវិញដោយ ដាក់ឯកសារផ្ទេរប្រាក់ ទៅកាន់សាច់ញាតិ។ សម្រាប់ព័ត៌មានលម្អិតសូមពិនិត្យការិយាល័យពន្ធដាក្នុងតំបន់របស់អ្នក។

អ្នកគួរតែយល់ពីអ្វីដែលត្រូវកាត់ និងអាចដកមកវិញរួចខំប្រឹងប្រែងក្នុងការបណ្តុះបណ្តាលបច្ចេកទេសដោយភាពជឿជាក់។

# 日本のお正月を楽しみました！

## ដំណើរកំសាន្តនៅរដូវចូលឆ្នាំ



●ヤマ・インダストリー／ON SOKHENG (កម្ពុជា)

ក្រោយពីបញ្ចប់ការងារក្នុងរយ:ពេលមួយឆ្នាំចៅកែបាននាំទៅវាយនំ(もちつき)និងបាននាំទៅមើលវត្តផងដែរ។ ពិតជាពេលវេលាដ៏មានតម្លៃណាស់។ខ្ញុំសូមអរគុណដល់ក្រុមហ៊ុនដែលបានផ្តល់បទពិសោធន៍ដ៏មានតម្លៃនេះ។

ヤマ・インダストリー合同会社／ソヘーンさん(カンボジア)

「会社の仕事納めに餅つきをして、年始に初詣に連れて行ってもらいました。餅つきを体験できてとても嬉しかったです。貴重な体験をさせてもらった会社に感謝です」





●北開技研工業／CHOR ROTHANA、PHON CHETA、THOEURN PHALLA (កម្ពុជា)

「បន្ទាប់ពីបានទៅមើលវត្តហើយពួកយើងបានទៅផ្ទះរបស់លោកនាយកគ្រប់គ្រងដើម្បីទទួលទានអាហារ។ពិតជាកក់ក្តៅណាស់」

北開技研工業株式会社／ロッタナーさん、チェタさん、ポラーさん(カンボジア)

「年始に初詣に行った後、専務さんのお宅で食事しました。心も身体も温まりました」

